World Health Organization
Western Pacific Region

# កម្ពុជា

## របាយការណ៍ស្តីពីស្ថានភាពជំងឺកូវីដ-១៩ លេខ#៦៤

២០ កញ្ញា ឆ្នាំ២០២១

របាយការណ៍គិតត្រឹមថ្ងៃទី ២០ កញ្ញា ឆ្នាំ២០២១ ម៉ោង១០:00នាទីព្រឹក

## ស្ថានការណ៍សង្ខេប

### សម្រង់សង្ខេបនៃរបាយការណ៍អំពីស្ថានភាពជំងឺកូវីដ-១៩ ពេលបច្ចុប្បន្ន

- ករណីវិជ្ជមានវីរុសកូវីដ-១៩ សរុបចំនួន ៤.៥៨៣ និងករណីស្លាប់ចំនួន ៧៤ ត្រូវបានរាយការណ៍នៅក្នុងរយៈពេល៧ថ្ងៃចុងក្រោយនេះ។ ក្នុងចំណោម ៤.៥៨៣ ករណីនោះ មានករណីនាំចូលចំនួន ៩៦២ (២១ ភាគរយ) និងករណីឆ្លងក្នុងស្រុកចំនួន ៣.៦២១ ឬស្មើនឹង ៧៩ ភាគរយ។
- ចាប់ពីថ្ងៃទី ៣១មីនា រហូតដល់ថ្ងៃទី ៩ខែកញ្ញាឆ្នាំ២០២១ ក្រសួងសុខាភិបាល បានរកឃើញវីរុសកូវីដ-១៩បំប្លែងថ្មី B.1.617.2 (ដែលតា) សរុបទាំងអស់ចំនួន ៣.៧៣១ ករណី (ស្រី១.៩០៤ករណី) នៅក្នុងរាជធានី-េខត្តចំនួន២៤ ក្នុងចំណោមពលករមកពីប្រទេសថៃ និងប្រទេសវៀតណាម អ្នកដំណើរមកតាមជើងហោះហើរ បុគ្គលិកសុខាភិបាល និងប្រជាពលរដ្ឋក្នុងសហគមន៍។
- គិតត្រឹមថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ២០២១ វេលាម៉ោង១០ ម៉ោងសកល ករណីសរុបទាំងអស់ចំនួន ១០៤.៧១៦ ត្រូវបានបញ្ជាក់ថាជាករណីវិជ្ជមានវីរុសកូវីដ-១៩ និងករណីស្លាប់ចំនួន ២.១២៣ ត្រូវបានរាយការណ៍ដោយរាជរដ្ឋាភិបាលកម្ពុជា។ ក្នុងចំណោមនោះ ៩៧.៧០០ ករណី បានជាសះស្បើយ។ ករណីនាំចូលពីក្រៅប្រទេសសរុបមានចំនួន ១៧.៩៩៥ ឬស្មើនឹង ១៧.២ ភាគរយនៃករណីជំងឺកូវីដ-១៩ ទាំងអស់។
- ចាប់តាំងពីខែមករា ឆ្នាំ២០២០ មក បុគ្គលសរុបចំនួន ១.៥៦២.១៣៤នាក់ បានធ្វើតេស្តរកវីរុសកូវីដ-១៩ ដោយប្រើបច្ចេកវិទ្យាធ្វើតេស្តប្រើម៉ាស៊ីននៅមន្ទីរពិសោធន៍ (Real-Time Polymerase Chain Reaction, RT-PCR) ដោយមានអត្រាវិជ្ជមានក្នុងកម្រិត ៥,៤ ភាគរយ។ ជាសរុប គិតត្រឹមថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ២០២១ ចំនួនតេស្ត ១.៩៤៤.០១៩ ត្រូវបានធ្វើដោយប្រើម៉ាស៊ីនតេស្តមន្ទីរពិសោធន៍។

## ព្រឹត្តិការណ៍ដែលនឹងកើតមាន និងវិធានការអាទិភាព

**ការតាមដានជំងឺ**

- ក្រសួងសុខាភិបាល ដោយមានការគាំទ្រពីអង្គការសុខភាពពិភពលោក កំពុងធ្វើការវាយតម្លៃ និងវិភាគស្ថានភាព និងដំណាក់កាលនៃការចម្លងប្រចាំសប្តាហ៍ ដើម្បីស្វែងយល់អំពីប្រសិទ្ធភាពនៃអន្តរាគមន៍នានា ដោយប្រើប្រព័ន្ធតាមដានជំងឺផ្អែកលើព័ត៌មានច្រើនប្រភពមកពីថ្នាក់ក្រោមជាតិ។
- អង្គការសុខភាពពិភពលោក កំពុងផ្តល់ការគាំទ្រដល់ក្រសួងសុខាភិបាលក្នុងការរៀបចំសេចក្តីណែនាំស្តីពីការតាមដានការអនុវត្ត និងអនុលោមតាមវិធានការសុខភាពសាធារណៈមិនមែនឱសថជាផ្នែកមួយនៃការតាមដាន និងវាស់វែងការអនុវត្តវិធានការសុខភាពសាធារណៈមិនមែនឱសថនៅថ្នាក់ក្រោមជាតិ។
- អង្គការសុខភាពពិភពលោក កំពុងផ្តល់ការគាំទ្រដល់ការត្រួតពិនិត្យមើលលើអត្រានៃការប្រើប្រាស់គ្រែសម្រាប់ព្យាបាលជំងឺធ្ងន់ នៅកម្រិតថ្នាក់ក្រោមជាតិ ហើយនិងពង្រឹងប្រព័ន្ធតាមដានជំងឺដើម្បីពិនិត្យតាមដានមើលករណីធ្ងន់ធ្ងរ ជាពិសេសនៅចំពោះមុខនៃការឆ្លងរីករាលដាលនៃមេរោគកូវីដ-១៩បំប្លែងថ្មីប្រភេទដែលតានៅក្នុងសហគមន៍។
- អង្គការសុខភាពពិភពលោក កំពុងបន្តផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដល់ក្រសួងសុខាភិបាលនៅក្នុងការពិនិត្យមើលឡើងវិញ និងធ្វើបច្ចុប្បន្នភាពយុទ្ធសាស្រ្តតាមដានជំងឺកូវីដ-១៩ ដើម្បីរៀបចំធ្វើការឆ្លើយតប។
- ក្រសួងសុខាភិបាលដោយទទួលបានការគាំទ្រផ្នែកបច្ចេកទេសពីអង្គការដៃគូ កំពុងតែស៊ើបអង្កេតករណីស្លាប់នៅក្នុងភូមិសាស្រ្តរាជធានីភ្នំពេញ ដើម្បីបង្កើនការយល់ដឹងពីមូលហេតុនៃការស្លាប់ ការទទួលបានការថែទាំ និងការចម្លងជំងឺកូវីដ-១៩នៅក្នុងសហគមន៍។
- ក្រសួងសុខាភិបាល រួមជាមួយនឹងអង្គការសុខភាពពិភពលោក បន្តពង្រឹងសមត្ថភាពក្រុមឆ្លើយតបបន្ទាន់នៅក្នុងខេត្តចំនួន៦ ដើម្បីស៊ើបអង្កេត និងប្រើប្រាស់របៀបតាមដានជំងឺដោយប្រើព័ត៌មានច្រើនប្រភពក្នុងការវាយតម្លៃស្ថានភាពអេពីដេមីសាស្រ្ត។



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

**មន្ទីរពិសោធន៍**

- វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា អង្គការសុខភាពពិភពលោក និងអង្គការដៃគូផ្សេងទៀត កំពុងផ្តល់ជំនួយផ្នែកបច្ចេកទេស និងផ្នែកសម្របសម្រួលដល់វិទ្យាស្ថានជាតិសុខភាពសាធារណៈ នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លងនៃក្រសួងសុខាភិបាល និងមន្ទីរពិសោធន៍វីរុសកូវីដ-១៩ ដើម្បីធានាឲ្យមាននិរន្តរភាពនៃសមត្ថភាពធ្វើតេស្ត។
- ផែនការពង្រីកមន្ទីរពិសោធន៍ កំពុងបន្តនៅមន្ទីរពិសោធន៍កំពុងដំណើរការស្រាប់ចំនួន១៦ ហើយការពង្រីមន្ទីរពិសោធន៍ចំនួន ៩ផ្សេងទៀតនឹងត្រូវធ្វើនៅក្នុងរយៈពេលប៉ុន្មានខែខាងមុខទៀត។ មន្ទីរពិសោធន៍ថ្នាក់តំបន់ដែលទើបសាងសង់ហើយថ្មីនៅខេត្តបាត់ដំបងបានដំណើរការហើយ។
- វិទ្យាស្ថានសុខភាពសាធារណៈ កំពុងពង្រឹងសមត្ថភាពវិភាគលំដាប់ហ្សែនទាំងមូល (whole genome sequencing) បន្ថែមទៅលើការវិភាគលំដាប់ហ្សែនទាំងមូលនៅវិទ្យាស្ថានប៉ាស្ទ័រ។
- វិទ្យាស្ថានជាតិសុខភាពសាធារណៈ បាននិងកំពុងធ្វើការជាមួយនឹងវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា អង្គការសុខភាពពិភពលោក និងដៃគូរៀបចំប្រព័ន្ធគ្រប់គ្រងសារពើភ័ណ្ឌ និងកម្មវិធីធានាគុណភាព (External Quality Assurance) សម្រាប់គ្រប់គ្រង និងធានាគុណភាពតេស្តនៅមន្ទីរពិសោធន៍រកវីរុសកូវីដ-១៩ទាំងអស់។
- អង្គការសុខភាពពិភពលោក កំពុងផ្តល់ការគាំទ្រដល់វិទ្យាស្ថានជាតិសុខភាពសាធារណៈនៅក្នុងការពង្រឹងសមត្ថភាពវិភាគលំដាប់ហ្សែនទាំងមូល (whole genome sequencing)ដើម្បីកំណត់រកវីរុសកូវីដ-១៩បំប្លែងថ្មី និងតាមដានរកមើលវីរុសបំប្លែងថ្មីដែលគួរឲ្យបារម្ភក៏ដូចជាវីរុសបំប្លែងថ្មីដែលគួរឲ្យចាប់អារម្មណ៍តាមរយៈការធ្វើលទ្ធកម្មសម្ភារមន្ទីរពិសោធន៍។
- អង្គការសុខភាពពិភពលោក កំពុងផ្តល់ជំនួយបច្ចេកទេស និងប្រឹក្សាយោបល់ដល់ក្រសួងសុខាភិបាលអំពីយុទ្ធសាស្ត្រយកសំណាកសម្រាប់ការតាមដានលំដាប់ហ្សែននៃវីរុសកូវីដ-១៩ និងបានរៀបចំពិធីសារមួយរួចហើយ។

**អន្តរគមន៍ និងការផ្តល់សេវាសុខភាព**

- បានផ្តល់ការគាំទ្រដល់ក្រសួងសុខាភិបាលក្នុងការបង្រៀនដោយផ្ទាល់ពីរបៀបព្យាបាលដោយប្រើអុកសីុសែនដែលនឹងត្រូវធ្វើឡើងនៅគ្រប់រាជធានី-ខេត្តទូទាំងប្រទេសនៅត្រឹមដំណាច់ឆ្នាំនេះ។ នៅសប្តាហ៍ក្រោយ ក្រុមការងារថ្នាក់ជាតិ នឹងបង្រៀនពីការព្យាបាលដោយ ប្រើអុកស៊ីសែនដល់បុគ្គលិកសុខាភិបាលផ្នែកព្យាបាលជំងឺធ្ងន់មកពីបណ្តាមន្ទីរពេទ្យ និងស្រុកប្រតិបត្តិខេត្តស្វាយរៀង និងខេត្តព្រៃវែង។
- បានផ្តល់ការគាំទ្រក្នុងការធ្វើបង្កើយបញ្ជីត្រួតពិនិត្យជំនាញប្រើឧបករណ៍ជំនួយដង្ហើមសម្រាប់ការព្យាបាលដោយប្រើអុកស៊ីសែន។
- បានផ្តល់ការគាំទ្រដល់នាយកដ្ឋានមន្ទីរពេទ្យក្នុងការធ្វើបង្កើយសូចនាករសម្រាប់តាមដានចំនួនគ្រែសម្រាប់ការព្យាបាលជំងឺធ្ងន់នៅកម្រិតថ្នាក់ក្រោមជាតិ និងពង្រឹងប្រព័ន្ធតាមដានជំងឺដើម្បីតាមដានភាពធ្ងន់ធ្ងរនៃករណី។
- ជួយដល់ការបណ្តុះបណ្តាលជាបន្តបន្ទាប់ដើម្បីគាំទ្រ និងពង្រឹងការផ្តល់សេវាសុខភាព ការបង្ការ និងការត្រួតពិនិត្យការចម្លងរោគ ការគ្រប់គ្រងគ្លីនិក ចំនួនគ្រែ និងប្រសិទ្ធភាពនៃការព្យាបាលអ្នកជំងឺធ្ងន់នៅតាមបណ្តាខេត្តជាប់ព្រំដែន។

**ការប្រាស្រ័យទាក់ទងអំពីហានិភ័យ និងការចូលរួមរបស់សហគមន៍**

- អង្គការសុខភាពពិភពលោក និងដៃគូ បន្តជម្រុញការចូលរួមរបស់សហគមន៍យ៉ាងសកម្មដោយផ្តោតជាសំខាន់ទៅលើកន្លែងដែលមានហានិភ័យខ្ពស់ ដើម្បីទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩។
- អង្គការសុខភាពពិភពលោក បានផ្តល់ការគាំទ្រដល់នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លងនៃក្រសួងសុខាភិបាល និងមជ្ឈមណ្ឌលជាតិលើកកំពស់សុខភាព ក្នុងការកែសម្រួល និងចែករំលែកសារសំខាន់ៗស្តីពីការបើកដំណើរការទីផ្សារប្រកបដោយសុវត្ថិភាព និងសុវត្ថិភាពចំណីអាហារ សុទិដ្ឋនិយមចំពោះវ៉ាក់សាំង និងធ្វើវាទាំងអស់ នៅលើទំព័រហ្វេសប៊ុករបស់នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង។
- អង្គការសុខភាពពិភពលោក កំពុងធ្វើការជាមួយអង្គការដៃគូដើម្បីដោះស្រាយបញ្ហាអនុវត្តតាមវិធានការដែលបានដាក់ចេញ នៅតាមបណ្តាទីតាំងសាងសង់ ដើម្បីលើកកំពស់វិធានការសុខភាពសាធារណៈ និងសង្គមក្នុងចំណោមកម្មករ។



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

- អង្គការសុខភាពពិភពលោក ដោយសហការជាមួយនឹងក្រុមហ៊ុនហ្វេសប៊ុក កម្មវិធីប្រាស្រ័យទាក់ទងរបស់មជ្ឈមណ្ឌល Jonhs Hopkins បានដាក់ឲ្យដំណើរការផ្ទាំងព័ត៌មានថ្មីស្តីពីការអនុវត្តវិធានការការពារជំងឺកូវីដ-១៩។ ផ្ទាំងព័ត៌មាន ត្រូវបានរចនាឡើងដោយអ្នកជំនាញផ្នែកប្រាស្រ័យទាក់ទងពីទិន្នន័យរបស់កម្មវិធីប្រាស្រ័យទាក់ទងនៃមជ្ឈមណ្ឌល Jonhs Hopkins ដើម្បីជួយសាធារណជនឈ្វេងយល់ពីនិន្នាការនៃចំណេះដឹង ឥរិយាបទ និងការអនុវត្តដែលជះឥទ្ធិពលដល់ការរីករាលដាលនៃជំងឺកូវីដ-១៩ នៅកម្រិតប្រទេស តំបន់ និងពិភពលោក។ ផ្ទាំងព័ត៌មាននោះ ក៏ជាការវិភាគជាលាយលក្ខណ៍អក្សរដែលត្រូវបានបង្កើតឡើងដោយអ្នកជំនាញសុខភាពពិភពលោកមកពីកម្មវិធីប្រាស្រ័យទាក់ទងរបស់មជ្ឈមណ្ឌល Jonhs Hopkins និងបណ្តាញរបស់អង្គការសុខភាពពិភពលោកសម្រាប់ការឆ្លើយតប និងជូនដំណឹងអំពីការផ្ទុះឡើងនៃជំងឺជាសកល (GOARN) ប្រែក្លាយការយល់ដឹងឲ្យទៅជាការអនុវត្ត និងរួចរាល់សម្រាប់ជួយដល់ការធ្វើសេចក្តីសម្រេចចិត្តអំពីគោលនយោបាយ យុទ្ធសាស្ត្រសម្រាប់យុទ្ធនាការ និងការបែងចែកធនធាន។
- សម្រាប់ព័ត៌មានអំពីកម្មវិធី Science in 5 របស់អង្គការសុខភាពពិភពលោកស្តីពីជំងឺកូវីដ-១៩ និយាយអំពីការចាក់វ៉ាក់សាំងដូសលាយគ្នានៅលើបណ្តាញយូធូប សូមចុចលើដំណរភ្ជាប់នេះ។

## ការវាយតម្លៃពីការចម្លង

ការវាយតម្លៃលើការតាមដានជំងឺដោយប្រើព័ត៌មានពីប្រភពចម្រុះនាពេលបច្ចុប្បន្ន បង្ហាញថា រាជធានីភ្នំពេញ ខេត្តព្រះសីហនុ ខេត្តកំពង់ស្ពឺ ខេត្តកណ្តាល ខេត្តតាកែវ ខេត្តកំពត ខេត្តបន្ទាយមានជ័យ ខេត្តកំពង់ចាម ខេត្តព្រៃវែង ខេត្តស្វាយរៀង ខេត្តត្បូងឃ្មុំ ខេត្តស្ទឹងត្រែង ខេត្តកំពង់ធំ ខេត្តសៀមរាប និងខេត្តឧត្តរមានជ័យ ស្ថិតនៅក្នុងដំណាក់កាលចម្លងទី២ (ការចម្លងកម្រិតសហគមន៍នៅតាមតំបន់) ហើយខេត្តចំនួន១០ផ្សេងទៀត (ខេត្តកោះកុង ខេត្តកំពង់ឆ្នាំង ខេត្តបាត់ដំបង ខេត្តកែប ខេត្តក្រចេះ ខេត្តប៉ៃលិន ខេត្តពោធិសាត់ ខេត្តខេត្តព្រះវិហារ ខេត្តមណ្ឌលគិរី និងខេត្តរតនគិរី) ស្ថិតនៅក្នុងដំណាក់កាលចម្លងទី១។

### បច្ចុប្បន្នភាពអេពីដេមីសាស្ត្រអំពីកូវីដ-១៩

| ចំនួនតេស្ត | ករណីឈឺ | ករណីស្លាប់ | |
|---|---|---|---|
| 55,445<br>ចំនួនតេស្តអាស៊ីតនុយក្លេអ៊ិចក្នុងពេល៧ថ្ងៃចុងក្រោយ | 4,583<br>ករណីវិជ្ជមានថ្មីក្នុងពេល៧ថ្ងៃចុងក្រោយ<br>(៤,៤ ភាគរយ - ៧ថ្ងៃ) | 74<br>ករណីស្លាប់ក្នុងពេល៧ថ្ងៃចុងក្រោយ<br>(៣,៥ ភាគរយ - ៧ថ្ងៃ) | 3,694<br>ករណីនាំចូលក្នុងពេល២៨ថ្ងៃចុងក្រោយ |
| 1,944,019<br>ចំនួនតេស្តអាស៊ីតនុយក្លេអ៊ិចសរុប | 104,716<br>ករណីសរុប | 2, 123<br>ករណីស្លាប់សរុប | 962<br>ករណីនាំចូលពីបរទេសក្នុងរយៈពេល៧ថ្ងៃចុងក្រោយ |

### ការផ្តល់សេវាសុខភាពអំពីកូវីដ-១៩

| | | |
|---|---|---|
| 225<br>ចំនួនមន្ទីរពេទ្យដែលទទួលព្យាបាលអ្នកជំងឺកូវីដ-១៩ | 13,782<br>ចំនួនគ្រែមន្ទីរពេទ្យរដ្ឋ | 116<br>ចំនួនមន្ទីរពេទ្យដែលមានបទពិសោធន៍គ្រប់គ្រងករណីជំងឺកូវីដ-១៩ (រួមមានមូលដ្ឋានថែទាំសុខាភិបាលចំនួន៩នៅរាជធានីភ្នំពេញ ២៧មន្ទីរពេទ្យខេត្ត និង ៨០មន្ទីរពេទ្យស្រុកប្រតិបត្តិ) |



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

# អេពីដេមីសាស្ត្រ

ក្រាហ្វិកទី១. ខ្សែកោងអេពីដេមីសាស្ត្រនៃករណីជំងឺកូវីដ-១៩ បែងចែកតាមកាលបរិច្ឆេទនៃរបាយការណ៍ឆ្នាំ២០២១




ក្រាហ្វិកទី២. ចំនួនករណីជំងឺស្រដៀងផ្តាសាយ (ILI) មកពីកន្លែងតាមដានជំងឺស្រដៀងផ្តាសាយ (ចំនួន ៧កន្លែង) ប្រចាំសប្តាហ៍ ឆ្នាំ២០២១ និងពីឆ្នាំ២០១៨ ដល់ឆ្នាំ ២០២០

*ការរាយការណ៍ពីកន្លែងតាមដានជំងឺស្រដៀងផ្តាសាយខ្លះមានការយឺតយ៉ាវ នៅក្នុងប៉ុន្មានសប្តាហ៍នេះ






**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

ក្រាហ្វិកទី៣. ចំនួនករណីជំងឺរលាកផ្លូវដង្ហើមស្រួចស្រាវធ្ងន់ធ្ងរ ប្រចាំសប្តាហ៍ ឆ្នាំ២០២១ និងពីឆ្នាំ២០១៧ ដល់២០២០






**បដិសេធការទទួលខុសត្រូវៈ** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

# អភិក្រមយុទ្ធសាស្ត្រ

**ការឆ្លើយតបសុខភាពសាធារណៈនៅថ្នាក់ជាតិ និងរាជធានី-ខេត្ត**

## ប្រព័ន្ធគ្រប់គ្រងឧប្បត្តិហេតុ

- គណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩ដែលមានសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីជាប្រធាន
    - គណៈប្រចាំការនៃគណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩ដែលមានឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាប្រធាន
    - គណៈកម្មការប្រយុទ្ធនឹងជំងឺកូវីដ-១៩ថ្នាក់រាជធានី-ខេត្តដែលដឹកនាំដោយអភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត
    - គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ក្នុងក្របខណ្ឌទូទាំងប្រទេស
    - គណៈកម្មការចំពោះកិច្ចទទួលបន្ទុកលទ្ធកម្មវ៉ាក់សាំងកូវីដ-១៩
- គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ដឹកនាំដោយរដ្ឋមន្ត្រីក្រសួងសុខាភិបាលជាប្រធាន និងអមដោយរដ្ឋលេខាធិការ
    - អនុគណៈកម្មការវាយតម្លៃ ផែនការ និងយុទ្ធសាស្ត្រដឹកនាំដោយរដ្ឋលេខាធិការក្រសួងសុខាភិបាល
    - អនុគណៈកម្មការគ្រប់គ្រងច្រកទ្វារចេញ-ចូលប្រទេស និងការធ្វើចត្តាឡីស័កដឹកនាំដោយអគ្គនាយកស្រាវជ្រាវចារកិច្ចក្រសួងការពារជាតិ
    - អនុគណៈកម្មការឆ្លើយតបបន្ទាន់ និងស្រាវជ្រាវរកបុគ្គលផ្ទុកមេរោគកូវីដ-១៩ ដឹកនាំដោយអគ្គស្នងការរងនរគបាលជាតិក្រសួងមហាផ្ទៃ
    - អនុគណៈកម្មការបច្ចេកទេស និងព្យាបាល ដឹកនាំដោយរដ្ឋលេខាធិការក្រសួងសុខាភិបាល
    - អនុគណៈកម្មការសេវាមន្ទីរពិសោធន៍ ដឹកនាំដោយរដ្ឋលេខាធិការក្រសួងសុខាភិបាល
    - អនុគណៈកម្មការអប់រំ បណ្តុះបណ្តាល និងទំនាក់ទំនងសាធារណៈ ដឹកនាំដោយរដ្ឋលេខាធិការក្រសួងសុខាភិបាល
    - អនុគណៈកម្មការបច្ចេកទេស និងទិន្នន័យ ដឹកនាំដោយរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
    - អនុគណៈកម្មការផ្គត់ផ្គង់ និងហិរញ្ញវត្ថុ ដឹកនាំដោយរដ្ឋលេខាធិការក្រសួងសុខាភិបាល
    - អនុគណៈកម្មការសាងសង់ និងជួសជុល ដឹកនាំដោយអគ្គស្នងការរងនគរបាលជាតិក្រសួងមហាផ្ទៃ
    - អនុគណៈកម្មការគ្រប់គ្រង និងចាត់ចែងសាកសពអ្នកជំងឺកូវីដ-១៩ ដឹកនាំដោយរដ្ឋលេខាធិការក្រសួងមហាផ្ទៃ
- គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយមានក្រុមការងារបច្ចេកទេស៤ក្រុមសម្រាប់ដោះស្រាយផលប៉ះបាល់ផ្នែកសេដ្ឋកិច្ច និងសង្គមបង្កឡើងដោយជំងឺកូវីដ-១៩

## ការអភិវឌ្ឍប្រព័ន្ធ និងគោលនយោបាយ

- កាលពីថ្ងៃទី៥ ខែមីនា ឆ្នាំ ២០២១ សេចក្តីព្រៀងច្បាប់ស្តីអំពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត ត្រូវបានអនុម័តដោយរដ្ឋសភា។
- ច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ដែលត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រិត្យនៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២០ មិនទាន់ត្រូវបានអនុវត្តនៅឡើយទេ។
- ទំរង់ Go.Data (Go.Data Platform) ត្រូវបានប្រើជាមូលដ្ឋានទិន្នន័យមួយសម្រាប់ប្រមូលព័ត៌មានអំពីអ្នកប៉ះពាល់ជាមួយករណីកូវីដ-១៩វិជ្ជមាន និងព័ត៌មានមន្ទីរពិសោធន៍។
- មូលដ្ឋានទិន្នន័យរបស់វិទ្យាស្ថានជាតិសុខភាពសាធារណៈ និងនាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង ត្រូវបានកែសម្រួលដើម្បីអាចបញ្ចូលសំណុំទិន្នន័យប្រភពច្រើនសម្រាប់ការធ្វើតេស្ត និងតាមដានជំងឺ។



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

## គន្លឹះអាទិភាពសំខាន់ៗ

- អង្គការសុខភាពពិភពលោក បានផ្តល់ការគាំទ្រដល់ក្រសួងសុខាភិបាលដើម្បីចុះបេសកកម្មទៅតាមបណ្តាខេត្តនានាក្នុងអំឡុងខែមិថុនាដល់ខែសីហា ដើម្បីជួយខេត្តក្នុងការត្រៀមរៀបចំខ្លួន និងឆ្លើយតបនឹងជំងឺកូវីដ-១៩។
- នាយកដ្ឋានមន្ទីរពេទ្យនៃក្រសួងសុខាភិបាល កំពុងធ្វើការស្ទង់មតិមួយអំពីវគ្គបណ្តុះបណ្តាលកន្លងមកពីការគ្រប់គ្រងគ្លីនិក ការបង្ការនិងត្រួតពិនិត្យការឆ្លងរោគ ដើម្បីរៀបចំបង្កើតកម្មវិធីសិក្សាថ្នាក់ជាតិមួយសំរាប់បញ្ហាជំងឺកូវីដ-១៩។
- នាយកដ្ឋានមន្ទីរពេទ្យនៃក្រសួងសុខាភិបាល កំពុងធ្វើការវាយតម្លៃទាក់ទងនឹងការត្រៀមខ្លួនរបស់ប្រព័ន្ធសុខាភិបាល នៅតាមមូលដ្ឋានថែទាំសុខភាព ទាក់ទងនឹងសមត្ថភាពសង្គ្រោះបន្ទាន់ (ICU) អុកស៊ីសែន បុគ្គលិកសុខាភិបាលជាដើម។
- កម្មវិធីថ្នាក់ជាតិកំពុងតែអភិវឌ្ឍផែនការឆ្លើយតប និងត្រៀមបង្ការដោយផ្តោតជាសំខាន់ទៅលើជំងឺកូវីដ-១៩។
- កំពុងដាក់ឲ្យអនុវត្តយុទ្ធសាស្រ្តពង្រីកមន្ទីរពិសោធន៍ និងផែនការធ្វើរោគវិនិច្ឆ័យម៉ូលេគុលដើម្បីធានាឲ្យមានការធ្វើតេស្តគ្រប់គ្រាន់ជាប្រចាំសម្រាប់ជំងឺកូវីដ-១៩នៅថ្នាក់ជាតិ និងថ្នាក់តំបន់។
- ការស្ទង់មតិមួយកំពុងត្រូវបានធ្វើឡើងនៅគ្រប់ខេត្តទាំងអស់ស្តីអំពីការប្រើប្រាស់តេស្តរហ័ស។
- ពង្រឹងសមត្ថភាពត្រៀមបង្ការនៅថ្នាក់មូលដ្ឋាន ក្នុងករណីមានការផ្ទុះរាលដាលជំងឺនៅសហគមន៍នាពេលអនាគត និងដើម្បីកាត់បន្ថយការរាំងស្ទះដល់ដំណើរការផ្តល់សេវាសុខភាពសំខាន់ៗ។

## អភិក្រមយុទ្ធសាស្រ្តសម្រាប់បង្ការ ស្រាវជ្រាវ និងត្រួតពិនិត្យជំងឺកូវីដ-១៩

- *យុទ្ធសាស្រ្តសម្រាប់ការធ្វើតេស្ត និងប្រព័ន្ធស្វែងរកអ្នកប៉ះពាល់មានរួចរាល់*

យុទ្ធសាស្រ្តធ្វើតេស្តទូលំទូលាយមួយ កំពុងត្រូវបានអនុវត្តនៅទូទាំងប្រទេស ដែលរួមមានការធ្វើតេស្តករណីសង្ស័យទាំងអស់ដែលចូលក្នុងនិយមន័យករណីសង្ស័យមានជំងឺកូវីដ-១៩ និងការឃ្លាំមើលយ៉ាងសកម្មចំពោះករណីជំងឺរលាកសាច់សួត (pneumonia) នៅតាមមន្ទីរពេទ្យ ក៏ដូចជាការធ្វើតេស្តនៅច្រកចេញ-ចូល (points of entry) នាថ្ងៃទី១ និងថ្ងៃទី១៣ ពេលបញ្ចប់ចត្តាឡីស័ក១៤ ថ្ងៃ និងការធ្វើតេស្តវត្ថុវិភាគបានមកពីប្រព័ន្ធតាមដានមានស្រាប់នៃជំងឺស្រដៀងផ្តាសាយ (ILI) និងជំងឺផ្លូវដង្ហើមស្រួចស្រាវធ្ងន់ធ្ងរ (SARI) ដើម្បីកំណត់រកមេរោគកូវីដ-១៩។ ការធ្វើតេស្តផ្តោតទៅលើក្រុមប្រជាជនដែលមានហានិភ័យខ្ពស់ (high-risk populations) កំពុងត្រូវបានអនុវត្តនៅពេលចាំបាច់។

- *ការប្រាស្រ័យទាក់ទងអំពីហានិភ័យ និងការចូលរួមរបស់សគមន៍*

យុទ្ធសាស្រ្តសម្រាប់ស្រាវជ្រាវរកជំងឺដោយមានការចូលរួមរបស់សហគមន៍ ត្រូវបានបង្កើតឡើង និងដាក់សាកល្បងដើម្បីស្វែករកករណីជំងឺកូវីដ-១៩ នៅកម្រិតមណ្ឌលសុខភាព និងនៅក្នុងសហគមន៍។ ក្រសួងមហាផ្ទៃ កំពុងជម្រុញការត្រួតពិនិត្យការធ្វើចត្តាឡីស័កតាមរយៈការតាមដាន និងពិន័យសម្រាប់បុគ្គលដែលបំពានគោលការណ៍ណែនាំ។

- *អន្តរាគមន៍សុខភាពសាធារណៈមិនមែនវេជ្ជសាស្រ្ត (មាននៅក្នុងតារាងនៅចុងបញ្ចប់នៃរបាយការណ៍នេះ)*



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

# បទពិសោធន៍ល្អៗ និងមេរៀនដែលទទួលបាន

## កត្តាដែលបានរួមចំណែកដល់ការឆ្លើយតបបានល្អ

- **ភាពជាអ្នកដឹកនាំខ្លាំង និងការសម្របសម្រួលបានល្អ**
  - ការឆ្លើយតបរបស់រដ្ឋាភិបាល និងសង្គមទាំងមូល ដឹកនាំដោយសម្តេចតេជោនាយករដ្ឋមន្ត្រី ហើយវិធានការសុខភាពសាធារណៈដឹកនាំដោយរដ្ឋមន្ត្រីសុខាភិបាល។
  - ផែនការមេថ្នាក់ជាតិសម្រាប់ប្រយុទ្ធនឹងជំងឺកូវីដ-១៩ ត្រូវបានរៀបចំឡើងជាមួយនឹងថវិកាចំនួន ៦២លានដុល្លារសហរដ្ឋអាមេរិកសម្រាប់ឆ្នាំទី១។
  - កាលពីថ្ងៃទី ០១ ខែកក្កដា ឆ្នាំ២០២១ សម្តេចនាយករដ្ឋមន្ត្រី បានដាក់ចេញនូវយុទ្ធសាស្ត្រស្តីអំពីការឆ្លើយតបចំពោះជំងឺកូវីដ-១៩ ចំនួន៦ចំណុចដោយផ្តោតទៅលើការការពារមិនឲ្យមានការនាំចូលវីរុសកូវីដ-១៩បំប្លែងថ្មី ការកាត់បន្ថយភូមិសាស្ត្រដែលមានការរីករាលដាលនៃជំងឺកូវីដ-១៩ និងចំនួនករណីឆ្លង ការផ្តល់ការព្យាបាលប្រកបដោយប្រសិទ្ធភាព និងស្តង់ដារ ការពង្រឹងការស្វែងរក និងគ្រប់គ្រងអ្នកដែលប៉ះពាល់អ្នកជំងឺ ការចាត់ចែងសាកសព និងវ៉ាក់សាំងការពារជំងឺកូវីដ-១៩។
- **ការវិនិយោគកន្លងមកបានពង្រឹងដំណើរការប្រព័ន្ធសុខភាពសុខភាពសាធារណៈ**
  - ការតាមដានជំងឺកូវីដ-១៩ ដោយបានពីព័ត៌មានពហុប្រភព រួមទាំងប្រព័ន្ធឃ្លាំមើលជំងឺកូវីដ-១៩ ដោយប្រើប្រព័ន្ធទូរស័ព្ទទាន់ហេតុការណ៍ (១១៥) និងប្រព័ន្ធតាមដានមានស្រាប់នៃជំងឺស្រដៀងផ្តាសាយ (ILI) និងជំងឺរលាកផ្លូវដង្ហើមស្រួចស្រាវធ្ងន់ធ្ងរ (SARI)។
  - ក្រុមឆ្លើយតបបន្ទាន់ជិត ៣.០០០នាក់ នៅទូទាំងប្រទេស បានស្រាវជ្រាវរកករណី និងតាមរកអ្នកប៉ះពាល់ជាមួយនឹងករណីវិជ្ជមានវីរុសកូវីដ-១៩។
- **ការទំនាក់ទំនង និងផ្សព្វផ្សាយហានិភ័យ និងការចូលរួមរបស់សហគមន៍**
  - សារទាន់ពេលវេលា ត្រូវបានផ្សព្វផ្សាយតាមទូរទស្សន៍ វិទ្យុ និងបណ្តាញសង្គម និងតាមរយៈសេចក្តីជូនព័ត៌មានទៀងទាត់ និងសន្និសីទសារព័ត៌មាន។
  - អភិក្រមដែលផ្អែកលើហានិភ័យសម្រាប់ការរៀបចំបង្កើតសម្ភារប្រាស្រ័យទាក់ទងជនគោលដៅ មានហានិភ័យខ្ពស់ ដូចជាជនទេសន្តប្រវេសន៍(ពលករចំណាកស្រុក) កម្មកររោងចក្រ ទីផ្សារលក់ដូរ ពន្ធនាគារ ភោជនីយដ្ឋាន-បារជាដើម ត្រូវបានបង្កើតឡើង។
  - យុទ្ធសាស្ត្រជម្រុញការចូលរួមរបស់សហគមន៍ ត្រូវបានអនុវត្តដើម្បីគ្របដណ្តប់គ្រប់ផ្នែកនៃការតាមដានជំងឺ និងការឆ្លើយតបចំពោះជំងឺកូវីដ-១៩ ជាពិសេសត្រៀមសម្រាប់ពេលមានការឆ្លងទៅសហគមន៍ណាមួយ។
  - មានកិច្ចសម្របសម្រួល និងសហប្រតិបត្តិការណ៍ជិតស្និទ ក្នុងចំណោមភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ និងអ្នកពាក់ព័ន្ធដទៃទៀត នៅក្នុងការអនុវត្តសកម្មភាពការងារលើកកំពស់ការចូលរួមរបស់សហគមន៍ និងការប្រាស្រ័យទាក់ទងអំពីហានិភ័យ ការតាមដាន កែសម្រួល និងពង្រឹងការអនុវត្ត។
- **សាមគ្គីភាព និងសហប្រតិបត្តិការអន្តរជាតិ**
  - ការឆ្លើយតបដោយប្រព័ន្ធសុខាភិបាលមួយដែលមានតម្លាភាព និងបើកចំហ។
  - កិច្ចសហការបច្ចេកទេស និងប្រតិបត្តិការជិតស្និទ្ធរវាងទីភ្នាក់ងារអង្គការសហប្រជាជាតិ និងដៃគូអភិវឌ្ឍន៍ដទៃទៀត។
  - ការចូលរួមនៃមន្ត្រីជាន់ខ្ពស់នៅកិច្ចប្រជុំអន្តរជាតិនានា រួមទាំងការសម្របសម្រួលជាទៀងទាត់ក្នុងចំណោមបុគ្គលិកទទួលបន្ទុកផ្នែកច្បាប់និយ័តកម្មអន្តរជាតិឆ្នាំ២០០៥ របស់អង្គការសុខភាពពិភពលោក។



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

## ការចាក់វ៉ាក់សាំងកូវីដ-១៩

គិតត្រឹមថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ២០២១៖

- **ចំនួនដូសវ៉ាក់សាំងដែលបានទទួលមកទល់នឹងបច្ចុប្បន្ន**

  រាជរដ្ឋាភិបាលកម្ពុជា ទទួលបានវ៉ាក់សាំងកូវីដ-១៩ សរុបទាំងអស់ចំនួន ២៩.៦០៦.៦០០ ដូស ដែលក្នុងនោះ៖
  - ចំនួន ២២.៥០០.០០០ដូស ឬស្មើនឹង ៧៦ ភាគរយតាមរយៈការបញ្ជាទិញពីសាធារណរដ្ឋប្រជាមានិត្យចិន
  - ចំនួន ៤.៧១៥.០០០ដូស ឬស្មើនឹង ១៦ ភាគរយតាមរយៈជំនួយពីសាធារណរដ្ឋប្រជាមានិតចិន និងចក្រភពអង់គ្លេស (៤.៣០០.០០០ដូស ជាជំនួយរបស់រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិត្យចិន និងចំនួន ៤១៥.០០០ដូសជាជំនួយរបស់រដ្ឋាភិបាលនៃចក្រភពអង់គ្លេស)។
  - ចំនួន ២.៣៩១.៦០០ដូស ឬស្មើនឹង ៨ ភាគរយតាមរយៈជំនួយពីមជ្ឈមណ្ឌលកូវ៉ាក់ (ដែលក្នុងនោះរួមមានជំនួយពីរដ្ឋាភិបាលជប៉ុន និងរដ្ឋាភិបាលសហរដ្ឋអាមេរិក)

- **លទ្ធផលយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩**

  ***១. លទ្ធផលចាក់វ៉ាក់សាំងសម្រាប់បុគ្គលមានអាយុចាប់ពី ១៨ឆ្នាំឡើង***

  - បុគ្គលចំនួន ៩.៨៣៣.៤៦៨ (ស្ត្រី ៥០ ភាគរយ) បានទទួលវ៉ាក់សាំងដូសទីមួយ។ បុគ្គលចំនួន ៨.៩៦៦.១១៧ (ស្ត្រី ៥០ ភាគរយ) បានទទួលវ៉ាក់សាំងដូសទីពីរ។ អត្រាគ្របដណ្តប់នៃការចាក់វ៉ាក់សាំងដូសទីមួយ គឺស្មើនឹង ៩៨ ភាគនៃប្រជាជនគោលដៅសរុប និងអត្រាគ្របដណ្តប់នៃការចាក់វ៉ាក់សាំងដូសទីពីរគឺស្មើនឹង ៩០ ភាគរយនៃជនគោលដៅសរុប។

  ***២. លទ្ធផលចាក់វ៉ាក់សាំងសម្រាប់កុមារ និងយុវជនអាយុចាប់ពី ១២ ឆ្នាំ ដល់ក្រោម១៨ឆ្នាំ***

  - កុមារ និងយុវជនអាយុចាប់ពី ១២ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ សរុបចំនួន ១.៧៣៣.៩៧៤ (៨៨ ភាគរយ) បានទទួលវ៉ាក់សាំងកូវីដ-១៩ដូសទីមួយ ហើយកុមារ និងយុវជនអាយុចាប់ពី ១២ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ សរុបចំនួន ១.៤៤៦.៦០៦ (៧៤ ភាគរយ) បានចាក់វ៉ាក់សាំងកូវីដ-១៩ដូសទីពីរ។
  - ភាគរយនៃកុមារី និងយុវនារីដែលបានទទួលដូសទីមួយ និងដូសទីពីរ មានចំនួន ៥០ភាគរយនៃចំនួនដូសសរុបដែលបានចាក់។

  ***៣. លទ្ធផលចាក់វ៉ាក់សាំងសម្រាប់កុមារ និងយុវជនអាយុចាប់ពី ៦ ឆ្នាំ ដល់ក្រោម១២ឆ្នាំ***

  - កុមារ និងយុវជនអាយុចាប់ពី ៦ឆ្នាំ ដល់ក្រោម ១២ឆ្នាំ សរុបចំនួន ៧០៨.៩៧១ (៣៧ ភាគរយ) បានទទួលវ៉ាក់សាំងកូវីដ-១៩ ដូសទីមួយ។
  - ភាគរយនៃកុមារី និងយុវនារីដែលបានទទួលដូសទីមួយ មានចំនួន ៥០ភាគរយនៃចំនួនដូសសរុបដែលបានចាក់។

  ***៤. លទ្ធផលចាក់វ៉ាក់សាំងដូសជម្រុញសម្រាប់បុគ្គលិកសុខាភិបាល និងមន្ត្រីរាជការជួរមុខ***

  - បុគ្គលិកសុខាភិបាល និងមន្ត្រីរាជការជួរមុខដែលមានអាយុចាប់ពី៦០ឆ្នាំឡើង និងអ្នកដែលមានប្រព័ន្ធភាពស៊ាំខ្សោយសរុបចំនួន 838.744នាក់ បានចាក់វ៉ាក់សាំងដូសជម្រុញ (ចំនួន៨៣៥,៩៧៩នាក់ បានចាក់វ៉ាក់សាំងអាស្ត្រាហ្សេណេកា និងចំនួន២,៧៦៥ នាក់ បានចាក់វ៉ាក់សាំងស៊ីណូវ៉ាក់)។
  - ភាគរយនៃស្ត្រីដែលបានទទួលដូសជម្រុញមានចំនួន ៣៦ភាគរយនៃចំនួនដូសសរុបដែលបានចាក់។

- ***សុវត្ថិភាពវ៉ាក់សាំងកូវីដ-១៩***

  ហេតុការណ៍កើតមានក្រោយពេលចាក់វ៉ាក់សាំង (AEFI) ចំនួន ២០៥ ករណី ត្រូវបានរាយការណ៍ពីខេត្តចំនួន ២៤ និងមន្ទីរពេទ្យជាតិចំនួន ៤។ អត្រានៃហេតុការណ៍កើតមានក្រោយពេលចាក់វ៉ាក់សាំង (AEFI) ក្នុងចំណោម ១០០.០០០ដូស គឺមាន០,៩១ ភាគរយ។



**បដិសេធការទទួលខុសត្រូវ៖** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

- អត្រានៃហេតុការណ៍កើតមានក្រោយពេលចាក់វ៉ាក់សាំង (AEFI) ក្នុងចំណោម ១០០.០០០ដូស សម្រាប់វ៉ាក់សាំងស៊ីណូវ៉ាក់ (៩៤ករណី) គឺមាន០,៧១ ភាគរយ។
- អត្រានៃហេតុការណ៍កើតមានក្រោយពេលចាក់វ៉ាក់សាំង (AEFI) ក្នុងចំណោម ១០០.០០០ដូស សម្រាប់វ៉ាក់សាំងស៊ីណូហ្វាម (៧៨ករណី) គឺមាន១,១៥ ភាគរយ។
- អត្រានៃហេតុការណ៍កើតមានក្រោយពេលចាក់វ៉ាក់សាំង (AEFI) ក្នុងចំណោម ១០០.០០០ដូស សម្រាប់វ៉ាក់សាំងអាស្ត្រាហ្សេណេកាកូវីសែល (២៩ករណី) គឺមាន៨,៩៧ ភាគរយ។
- អត្រានៃហេតុការណ៍កើតមានក្រោយពេលចាក់វ៉ាក់សាំង (AEFI) ក្នុងចំណោម ១០០.០០០ដូស សម្រាប់វ៉ាក់សាំង Johnson & Johnson (៤ករណី) គឺមាន០,៣៩ ភាគរយ។

## អន្តរាគមន៍សុខភាពសាធារណៈមិនមែនឱសថ (Non-Pharmaceutical Interventions)

កាលពីថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ២០២១ រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងជាប្រធានគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ បានក្រើនរំលឹកដល់អាជ្ញាធររាជធានីខេត្តទាំងអស់យកចិត្តទុកដាក់ខ្ពស់ជាបន្តទៀតក្នុងការអនុវត្តយុទ្ធនាការជាតិ "រួមគ្នាទទួលខុសត្រូវទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩" ឲ្យបានខ្ជាប់ខ្ជួនតាមរយៈ៖

- ការបន្តជម្រុញការអប់រំផ្សព្វផ្សាយខ្លឹមសារ នៃយុទ្ធនាការជាតិក្នុងចំណោមបុគ្គល គ្រួសារ និងសហគមន៍
- ការជម្រុញការអនុវត្តបានខ្ជាប់ខ្ជួននូវវិធានការ៣ការពារ និង ៣កុំ
- ការណែនាំ និងផ្សព្វផ្សាយ និងតាមដានជាប្រចាំលើការអនុវត្តវិធានការសុខាភិបាលនៅតាមទីតាំងនានា ជាពិសេសទីតាំងដែលមានហានិភ័យខ្ពស់ទីតាំង ៣ "ជ"
- ការចាត់វិធានការរដ្ឋបាល និងវិធានការច្បាប់ដល់បុគ្គល ឬអាជីវកម្មណាដែលមិនគោរពតាមគោលការណ៍ណែនាំរបស់ក្រសួងសុខាភិបាល ស្របតាមច្បាប់ជាធរមាន។

កាលពីថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ២០២១ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តម្រូវឲ្យម្ចាស់ ឬនាយករោងចក្រសហគ្រាសទាំងអស់ អនុញ្ញាតឲ្យកម្មករនិយោជិតទាំងអស់របស់ខ្លួនឈប់សម្រាកដោយមានប្រាក់ឈ្នួលចំនួនបីថ្ងៃក្នុងពិធីបុណ្យភ្ជុំបិណ្ឌខាងមុខនេះ គឺពីថ្ងៃទី ៥រហូតដល់ថ្ងៃទី ៧ខែតុលាឆ្នាំ២០២១។ ម្ចាស់ ឬនាយករោងចក្រសហគ្រាស អាចពិភាក្សាជាមួយតំណាងកម្មករនិយោជិត ក្នុងការរៀបចំ ឬផ្លាស់ប្តូរការឈប់សម្រាកនេះនៅពេលណាមួយផ្សេងទៀតក្នុងករណីមានការព្រមព្រៀងពីកម្មករនិយោជិត។ ចំពោះរោងចក្រសហគ្រាសដែលកម្មវត្ថុអាជីវកម្មមានចរិតលក្ខណៈសកល ត្រូវប្រព្រឹត្តទៅជាប្រចាំ និងមិនអាចបញ្ឈប់សកម្មភាពបាន ហើយការឈប់សម្រាកបុណ្យនៃកម្មករនិយោជិតទាំងអស់ព្រមគ្នាក្នុងពេលតែមួយនាំឲ្យខូចប្រយោជន៍ដល់សាធារណៈជន ឬក៏ធ្វើឲ្យខូចដំណើរការរបស់រោងចក្រសហគ្រាសនោះ ម្ចាស់ ឬនាយករោងចក្រសហគ្រាស ត្រូវរៀបចំបែងចែកឲ្យកម្មករនិយោជិត បានឈប់សម្រាកទៅតាមថ្ងៃបុណ្យនីមួយៗ ដោយផ្លាស់ប្តូរគ្នា ហើយរក្សាទុកបញ្ជីបែងចែកនោះជាប្រចាំសម្រាប់ការត្រួតពិនិត្យរបស់អធិការការងារ។ កម្មករនិយោជិតដែលធ្វើការថ្ងៃឈប់បុណ្យភ្ជុំបិណ្ឌនេះ មានសិទ្ធិទទួលនូវប្រាក់បំណាច់បន្ថែមដែលមានចំនួនស្មើនឹងប្រាក់ឈ្នួលថ្ងៃធ្វើការធម្មតា។

ខណៈដែលពិធីបុណ្យភ្ជុំបិណ្ឌ នឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី២២ ខែកញ្ញាឆ្នាំ២០២១ រហូតដល់ថ្ងៃទី ៦ខែតុលាឆ្នាំ២០២១ រដ្ឋបាលខេត្តចំនួន៧ដែលរួមមានរដ្ឋបាលខេត្តកំពង់ចាម ខេត្តកោះកុង ខេត្តឧត្តរមានជ័យ ខេត្តប៉ៃលិន ខេត្តព្រះសីហនុ ខេត្តព្រះវិហារ និងខេត្តរតនគិរី បានចេញសេចក្តីណែនាំឲ្យមន្ទីរធម្មការ និងសាសនាខេត្ត រដ្ឋបាលក្រុង ស្រុក និងឃុំសង្កាត់ វត្តអារាម ក៏ដូចជាពុទ្ធបរិស័ទត្រូវអនុវត្តតាមវិធានការសុខាភិបាល និងវិធានការរដ្ឋបាល តាមការណែនាំរបស់រាជរដ្ឋាភិបាល និងក្រសួងសុខាភិបាលឲ្យបានខ្ជាប់ខ្ជួននៅក្នុងពេលប្រារព្ធពិធីបុណ្យកាន់បិណ្ឌ និងភ្ជុំបិណ្ឌរយៈពេល១៥ថ្ងៃខាងមុខនេះ។

ក្នុងរយៈពេលមួយសប្តាហ៍កន្លងមក៖

- រដ្ឋបាលខេត្តកណ្តាល តម្រូវឲ្យធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ រៀបចំតេស្តរហ័សរក្សមេរោគកូវីដ-១៩ដល់បុគ្គលិករបស់ខ្លួនជាប្រចាំ។ រដ្ឋបាលខេត្តបាត់ដំបងដាក់ចេញនូវវិធានការរដ្ឋបាលដោយផ្អាកជាបណ្តោះអាសន្នចំពោះសកម្មភាពការងារ មុខរបរ ឬអាជីវកម្មដែលមានហានិភ័យខ្ពស់នៃការឆ្លងរាលដាលជំងឺកូវីដ-១៩ និងការជួបជុំ ឬការប្រមូលផ្តុំមនុស្សជាលក្ខណៈឯកជន ខណៈដែលរដ្ឋបាលខេត្តចំនួន ៥ផ្សេងទៀត (រដ្ឋបាលខេត្តកំពង់ចាម ខេត្តកែប ខេត្តឧត្តរមានជ័យ ខេត្តព្រះសីហនុ និងខេត្តព្រះវិហារ) បន្តអនុវត្តវិធានការរដ្ឋបាលដោយផ្អាកជាបណ្តោះអាសន្នចំពោះសកម្មភាពការងារ មុខរបរ ឬអាជីវកម្មដែលមានហានិភ័យខ្ពស់នៃការឆ្លងរាលដាលជំងឺកូវីដ-១៩ និងការជួបជុំ ឬការប្រមូលផ្តុំមនុស្សជាលក្ខណៈឯកជន និងបម្រាមលក់ដូរគ្រឿងស្រវឹងគ្រប់ប្រភេទ។



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

- រដ្ឋបាលខេត្តកំពង់ចាម បន្តអនុវត្តបម្រាមគោចរ រីឯរដ្ឋបាលខេត្តសៀមរាបដាក់ឲ្យអនុវត្តបម្រាមគោចរ ការដាក់សង្កាត់ជាច្រើននៅក្រុងសៀមរាប និងឃុំជាច្រើននៅក្នុងស្រុកចំនួនពីរ ជាតំបន់ក្រហម និងតំបន់លឿងទុំ ហើយរដ្ឋបាលខេត្តព្រះវិហារ និងខេត្តឧត្តរមានជ័យ បានដាក់អនុវត្តវិធានការបិទខ្ទប់ និងដាក់ជាតំបន់ក្រហម និងតំបន់លឿង។
- ក្រុមហ៊ុនស្រាបៀរកម្ពុជា ខេមប្រ៊ូវ (ស្រាបៀរអង្គរ) នៅខេត្តព្រះសីហនុ និងទីតាំងផ្សារចំនួន៤នៅខេត្តសៀមរាប និងខេត្តស្វាយរៀង ត្រូវបានបិទជាបណ្តោះអាសន្ន រីឯទីតាំងផ្សារចំនួន២ នៅខេត្តកំពង់ឆ្នាំង និងខេត្តព្រះសីហនុត្រូវបិទជាបណ្តោះអាសន្ន។
- រដ្ឋបាលខេត្តបាត់ដំបង ខេត្តកំពង់ចាម ខេត្តកោះកុង និងខេត្តស្វាយរៀង បានបើកដំណើរការសាលារៀនកម្រិតអនុវិទ្យាល័យ និងវិទ្យាល័យឡើងវិញ។



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

**តារាងទី២ . ការអនុវត្តអន្តរាគមន៍សុខភាពសាធារណៈមិនមែនឱសថ និងថ្ងៃដែលលើកបម្រាមវិញ (NPI implementation and lifting dates)**

| អន្តរាគមន៍សុខភាពសាធារណៈមិនមែនឱសថ (NPI) | ស្ថានភាពត្រួតពិនិត្យ (Monitoring status) | | | | | |
|---|---|---|---|---|---|---|
| | | | ការអនុវត្ត (Implementation) | | ការលើកបម្រាមវិញដោយផ្នែក (Partial lift) | លើកបម្រាមវិញ (Lifted) |
| | ថ្ងៃទី១នៃការអនុវត្ត (Date first implemented) | ថ្ងៃកែប្រែចុងក្រោយ (Date last modified) | ភូមិសាស្ត្រ (ថ្នាក់ជាតិ ឬថ្នាក់ក្រោមជាតិ) Geographical (national or sub-national) | ណែនាំឲ្យ ឬតម្រូវឲ្យ (Recommended or Required) | លើកសម្រាប់វិស័យ/ផ្នែកខ្លះ (Lifted for some area) | លើកសម្រាប់វិស័យ/ផ្នែកទាំងអស់ (Lifted for all areas) |
| ពាក់ម៉ាស់ការពារ អនាម័យដៃ និងផ្លូវដង្ហើម | មិនមានទេ (None) | ០៣ ឧសភា ឆ្នាំ២០២១ | ថ្នាក់ជាតិ | តម្រូវឲ្យ (Required) | | មិនទាន់លើកទេ (No) |
| បិទសាលារៀន (School Closure) | ១៦ មិនា ឆ្នាំ២០២០ | ១៩ មិថុនា ឆ្នាំ២០២១ | ថ្នាក់ជាតិ | តម្រូវឲ្យ (Required) | មិនទាន់លើកទេ (No) | មិនទាន់លើកទេ (No) |
| បិទកន្លែងធ្វើការ (Workplace Closure) | មិនមានទេ (None) | មិនមានទេ (None) | | | | |
| ការជួបជុំមនុស្សម្នាច្រើន (Mass Gatherings) | ៣ មេសា ឆ្នាំ២០២០ | ១៩ មិថុនា ឆ្នាំ២០២១ | ថ្នាក់ជាតិ | តម្រូវឲ្យ (Required) | មិនទាន់លើកទេ (No) | មិនទាន់លើកទេ (No) |
| នៅផ្ទះ (Stay at Home) | រដ្ឋាភិបាលស្នើឲ្យនៅផ្ទះប្រសិនបើអាចធ្វើបាន (Government recommends stay home if possible) | មិនមានទេ (None) | | | | |
| រឹតបន្តឹងការធ្វើដំណើរនៅក្នុងប្រទេស (Restrictions on Internal Movement (within country)) | ៩ មេសា ឆ្នាំ២០២០ | ២៩ កក្កដា ឆ្នាំ២០២១ | ថ្នាក់ជាតិ | ណែនាំឲ្យ (Recommended) | បានលើកហើយ (Yes) | មិនទាន់លើកទេ (No) |
| ការរឹតបន្តឹងលើការធ្វើដំណើរអន្តរជាតិ (Restrictions on International Travel) | ២៧ មិនា ឆ្នាំ២០២០ | ១១ វិច្ឆិកាឆ្នាំ២០២០ | ថ្នាក់ជាតិ | តម្រូវឲ្យ (Required) | បានលើកហើយ (Yes) | មិនទាន់ទេ (No) |
| ផ្សេងៗទៀត សូមបញ្ជាក់ដោយពណ៌នា (Others; specify in narrative) | មិនមានទេ (None) | មិនមានទេ (None) | - | - | - | - |



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។